Reading Book

# ពិភពរឿងនិទាន

*The World of Stories*



# ខ្មោចដើមចេកជ្វា

# Ghost on Large Banana Tree

សៀវភៅជាឃ្លាំងនៃចំណេះដឹង

*Books are the source of knowledge*

ចាស់បុរាណខ្មែរយើងច្រើនជឿហើយហាមប្រាមកូនចៅមិនឱ្យដាំដើមចេកជ្វានៅជិតសំយាបផ្ទះ ព្រោះគេយល់ថា វាដាក់ម្ចាស់ផ្ទះ។ បានជាមានជំនឿយ៉ាងនេះ ព្រោះមានរឿងដំណាលដូចតទៅ ៖



There is an old saying that the ancient Cambodian people had belief and often told their descendants not to grow Chek Chvea (a kind of Large Banana Tree) adjacent to the end pieces of house roofs because it was believed that this might bring bad luck to the house owner. This belief was derived from the following story:



ជាយូរអង្វែងណាស់មកហើយ មានគ្រួសារមួយទីទ័លក្រ។ ពួកគាត់ជាកសិករ។ នារដូវមួយដែលធាតុអាកាសកំពុងរាំងស្ងួតឥតមានភ្លៀងធ្លាក់សម្រាប់ធ្វើស្រែឡើយ។ បុរសជាប្តីក៏សុំប្រពន្ធទៅរកស៊ីឈ្នួលគេនៅស្រុកឆ្ងាយ។

Long, long time ago, there lived a poor family who were farmers. One day during a drought, there was no water or rain for farming. The man, then, decided to leave his wife to work as laborer in a far-away village.

ក្រោយពេលដែលបុរសនោះចេញទៅផុត ស្រុកក៏កើតជំងឺអាសន្នរោគរាតត្បាតពាសពេញស្រុកបណ្ដាលឱ្យអ្នកភូមិទាំងមូលភ័យជ្រួលច្របល់យ៉ាងខ្លាំង។ មុនដំបូងជំងឺនេះចាប់ផ្ដើមឡើងពីសត្វតូចតាចតែប៉ុណ្ណោះ។ លុះយូរបន្តិចទៅក៏រាលដាលរហូតដល់សត្វធំៗរហូតដល់ជីវិតមនុស្សក្នុងភូមិស្លាប់ជាបន្តបន្ទាប់គ្មាននរណាអាចជួយនរណាបានឡើយ។

After the husband left, there was an epidemic of cholera in the village where his wife lived. This outbreak made the villagers very frightened. At the beginning, only small animals were infected with the disease, but later on, it spread out to the big animals and then to human beings, killing a series of them . No one was able to help other ones.



ផ្ទះនីមួយៗមានសភាពស្ងាត់ជ្រងំ។ ពេលយប់គេឮសូរតែសម្លេងឆ្កែលូ និងពន្លឺភ្លើងចង្កៀងផ្លុងៗត្រង់នេះមួយ ត្រង់នោះមួយគួរឱ្យព្រឺក្បាលពន់ពេក។ នៅភូមិខ្លះដែលរោគនេះមិនទាន់រាលដាលទៅដល់ អ្នកនិគមជនបទទាំងនោះ ក៏ពុំហ៊ានដើរស្វែងរកប្រកបកិច្ចការរហេតរហូតដូចប្រក្រតីឡើយ។ មនុស្សទាំងនោះមានកិរិយាស្ងប់ស្ងៀមមានទឹកមុខក្រៀមក្រំស្រពាប់ស្រពោនជានិច្ច និយាយរកគ្នាទៅវិញទៅមកដោយការខ្សឹបខ្សៀវ មិនហ៊ាននិយាយគ្នាកកោកកកាក ឬនឹកឈ្មោះទីកន្លែងដែលកើតជំងឺចង្រៃនោះឡើយ។



Each house was so quiet. In the night, only the sound of dogs howling was heard and the gentle light of kerosene lamps was seen in sparse places, causing everyone to have goose dimples on their skin, just to think of it. In some villages where the disease had not yet been spread to people and animals, the villagers in those remote areas were scared to earn their living as usual. They were very upset and quiet, only whispered to each other, not dared to talk loudly or to think of where the incident happened.



មានថ្ងៃមួយ នៅពេលដែលជំងឺនេះកំពុងតែបង្កើនឥទ្ធិពលយ៉ាងខ្លាំងក្លា ស្រាប់តែមានអ្នកស្រុកម្នាក់មកនិមន្តលោកគ្រូចៅអធិការវត្តទៅចំរើនព្រះបរិត្តនៅឯផ្ទះរបស់ខ្លួន។ លុះដល់ពេលកំណត់អ្នកស្រុកម្នាក់នោះក៏មកទទួលព្រះថេរៈព្រមទាំងភិក្ខុពីរអង្គទៀតទៅផ្ទះរបស់គេ។



One day while the disease was spreading out fiercely, there was a generous person coming to invite a Buddhist monk to recite a protective prayer at his home. When it was the time to take the monks, he came to get a senior monk and two ordinary monks.

នៅពេលដែលលោកនិមន្តទៅដល់ផ្ទះឧបាសកនោះ គេឃើញមានភ្ញៀវយ៉ាងច្រើន។ គេបាននិមន្តព្រះសង្ឃទាំងបីអង្គឡើងទៅលើផ្ទះគង់លើអាសនៈយ៉ាងសមគួរ ហើយប្រគេនភេសជ្ជៈ តែ ស្ករ បារី តាមទំនៀមទំលាប់។ បន្ទាប់មកគេក៏នាំគ្នានមសិការព្រះរតនត្រ័យរួចអារាធនាព្រះសង្ឃចំរើនព្រះបរិត្ត។ ប៉ុន្តែឧបាសកទូលលោកថា "សូមព្រះតេជគុណកុំសូត្រធម៌ករណីយ៍អី សូមនិមន្តសូត្ររំលងទៅវិរូបក្ខេតែម្តងទៅដើម្បីកុំឱ្យយូរពេល។ ព្រះសង្ឃចាប់ផ្តើមចំរើនព្រះបរិត្តតាំងពីដើមរៀងទៅ។ លុះដល់ធម៌ករណីយ៍ លោកក៏រំលងទៅសូត្រវិរូបក្ខេតាមពាក្យទាយកបវារណាសុំតែម្តង។



When the monks arrived at his home, there were many guests. The three monks were invited to come onto the house and sat on good seats, and then they were traditionally offered drinks, tea, sugars and cigarettes. After that, the people did recitation as a respect for the three jewels (Buddha, Dharma and Sangha) and then it was the monks' turn to recite a protective prayer. But the layman said, 'Would you please not recite Dharma of Karanei to frighten the spiritual evil; rather, skip to recite the Dharma of Viropake right away in order to save time?' The monks started to recite the protective prayer from the beginning, as requested by the layman, skipping the Dharma of Karanei and moving to Dharma of Viropake.

ខណៈពេលនោះ លោកសង្កេតឃើញទាយកទាយិកាសប្បាយរីករាយ សើចញញឹមញញែមក្របួចមាត់ក្របួចកគ្រប់ៗគ្នា។ ព្រះថេរៈដើមអាសនៈ ឆ្ងល់ថា "គេសុំកុំឱ្យសូត្រធម៌ករណីយ៍ ឱ្យផ្លោះទៅសូត្រវិរូបក្ខេតែម្ដង ឥឡូវសូត្រវិរូបក្ខេទៅ ស្រាប់តែគេនាំគ្នាសើចសប្បាយបែបដូចជាប្លែក"។ ព្រះថេរៈនឹកអៀនក្នុងព្រះទ័យណាស់ ខ្លាចក្រែងគេរិះគន់ថា លោកសូត្រខុស ទើបត្រលប់មកចាប់សូត្រធម៌ករណីយ៍វិញ។

Suddenly the monks noticed that all generous people were pleased and laughed happily. "They have asked us not to recite Dharma of Karanei and requested us to move right to Dharma of Viropake, but why they turned laughing, it is very odds" doubted the senior monk on the first seat. He was very ashamed and worried that he would be criticized of this mistake, so he went back to Dharma of Karanei.



លោកទើបតែនឹងចាប់សូត្របាន៣-៤ព្រះឱស្ឋ ស្រាប់តែទាយកទាយិកានាំគ្នាដកខ្លួនថយបន្តិចម្តងៗរហូតដល់អស់មនុស្សស្ងាត់ឈឹង។ ភ្លើងទៀនក៏រលត់ភ្លឹប។ ផ្ទះដែលព្រះសង្ឃគង់នៅនោះត្រលប់ទៅជាគុម្ពឫស្សីយ៉ាងញាតស្បាត រីឯបារីតែស្ករទៅជាដុំធ្យូង ដីខ្សាច់និងកំណាត់ឈើអស់រលីង។ ទើបព្រះសង្ឃភ្ញាក់ថា ជាបិសាចក្លែងខ្លួនធ្វើជាមនុស្សមកបន្លំខ្លួន។ ទំរាំតែញាតិញោមនៅឯវត្តបានដឹងព្រះសង្ឃទាំងបីអង្គត្រូវអត់ចង្ហាន់ដល់ទៅ២-៣ថ្ងៃឯណោះ។



No sooner had the monks recited few words than all the generous people suddenly left one by one until the place was empty. Then the candle flame went out immediately. The house where the monks were staying became the thickest dense of bamboo, whereas the cigarettes, tea, and sugar turned out to be charcoal, sand and chopped wood. At that moment, the monks realized that the ghosts had transformed themselves as humans to invite them. Until the laymen and laywomen at the pagoda knew this, the three monks had no food to eat for nearly three days.



ដោយហេតុហ្នឹងហើយ ទើបចាស់បុរាណលោកតែងតែនិយាយថា ធម៌ករណីយ៍នេះធ្វើឱ្យខ្មោចខ្លាចណាស់។ ឯធម៌វិរូបក្ខេធ្វើឱ្យខ្មោចសប្បាយទៅវិញ។ កាលណាស្រុកមិនសូវស្រួលដោយមានកើតជំងឺជង្ការផ្សេងៗ មានអាសន្នរោគ អុតជាដើមនោះ គេតែងនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ហើយសុំឱ្យលោកសូត្រធម៌ករណីយ៍នេះឱ្យបាន៧-៨ចប់ ហើយហាមផ្តាច់មិនឱ្យព្រះសង្ឃសូត្រធម៌វិរូបក្ខេឡើយ ដោយមានជំនឿតាមរឿងដូចបានរៀបរាប់មកខាងលើនេះ។ ម្យ៉ាងទៀតបុរាណមានជំនឿថា បើយើងដើរទៅណាមកណានៅពេលយប់ ហើយមានព្រឺរោមព្រឺស្បែកត្រូវឱ្យសូត្រធម៌ករណីយ៍នេះដោយសំអាងថា ខ្មោចមិនលង ហើយខ្មោចខ្លាចធម៌ករណីយ៍នេះណាស់។

Therefore, it has been said that the Dharma of Karanei makes ghost very scared, while Dharma of Viropake makes them happy. When the villages are attacked by the diseases such as cholera, plague and so on, the villagers always invite monks to recite the protective prayer and request them to recite Dharma of Karanei seven to eight times, and not to recite Dharma of Viropake, since there was a story narrated above. Besides, people in the ancient time believed that when they needed to go somewhere in the night and if they had goose dimples, they had to recite Dharma of Karanei, believing that the ghost would not haunt, but rather the ghost would be afraid of Dharma Karanei very much.

និយាយពីបុរសនោះវិញ បន្ទាប់ពីបានទៅរកស៊ីមានលុយកាក់សមល្មម ហើយ ក៏វិលត្រលប់មកស្រុកកំណើតវិញ។ លុះមកដល់ពាក់កណ្ដាលផ្លូវ មានគេនិយាយប្រាប់ថា "អ្នកឯងទៅភូមិនោះមិនទាន់បានទេព្រោះមនុស្ស នៅក្នុងភូមិអ្នកឯង កំពុងកើតជំងឺអាសន្នរោគស្លាប់អស់ច្រើនណាស់ រីឯ ប្រពន្ធកូនរបស់អ្នកឯងប្រហែលជាស្លាប់ ឬយ៉ាងណាក៏មិនដឹងដែរ ព្រោះ ឥឡូវឥតមាននរណាម្នាក់ហ៊ានចូលទៅក្នុងភូមិនោះឡើយ។ ដោយ បុរសនោះមានសេចក្ដីនឹករលឹកដល់ប្រពន្ធកូនខ្លាំងពេក ក៏ចចេសដើរទៅ ផ្ទះរបស់ខ្លួន។ គាត់ខំធ្វើដំណើរទៅទាំងយប់ទាំងសស្លាក់សស្លើត។

Talking about the man who went to work as laborer, after he earned enough money, he returned home. On the halfway home, he was told, "You can't go to your village now, since the people there are infected with cholera and many of them have died. We don't know whether your children and your wife are still alive or not, because now no one is encouraged to go to the village." Because the man missed his wife and children, he stubbornly walked to his home. He hastened back to his home in that night.



លុះទៅជិតដល់លំនៅខ្លួន មើលទៅឃើញភ្លើងផ្លូងៗគ្រប់ផ្ទះដូចប្រក្រតី គាត់ត្រេកអរណាស់ ហើយនឹកខឹងនឹងអ្នកស្រុកទាំងអស់នោះដែលនិយាយកុហក។ ប៉ុន្តែនៅតាមផ្លូវទៅកាន់ផ្ទះគាត់ៗមានសេចក្តីសង្ស័យខ្លះៗដែរ ចំពោះសភាពស្ងប់ស្ងាត់ខុសប្លែកពីធម្មតា តែគាត់សន្និដ្ឋានថាប្រហែលជាអ្នកស្រុកមិនស្រួលមែនហើយទើបស្ងាត់យ៉ាងនេះ។ លុះទៅដល់របងផ្ទះ ក៏ស្រែកហៅប្រពន្ធ។ ពេលនោះគាត់ក៏ឃើញប្រពន្ធគាត់រត់មកទទួលយ៉ាងរាក់ទាក់ដូចធម្មតាគ្មានអ្វីគួរឱ្យសង្ស័យឡើយ។

When he arrived near his house, he saw the dim light in every house; he was very happy and came up with the feeling of anger towards the villagers who had told him a lie. But he felt a slight doubtful on the way home for the unusual quietness, he suggested that there might be something happening to the villagers. Reaching the fence of his house, he called for his wife. At the moment, he saw his wife coming to welcome him warmly as usual; there seemed nothing to be suspicious.





នាងនោះខំប្រញាប់ទៅបង្កាត់ភ្លើងដាំបាយឱ្យប្ដីបរិភោគ ប៉ុន្តែនាងហាមប្ដីមិនឱ្យចូលទៅក្នុងបន្ទប់ដេកទេ ឱ្យប្ដីសម្រាកនៅខាងក្រៅសិន។ ប្ដីនឹកឆ្ងល់នឹងឥរិយាបថដ៏ចម្លែករបស់ភរិយាណាស់ ដោយគាត់សង្កេតឃើញភ្នែករបស់នាងធំៗ លៀនៗបែបក្រហម ហើយក្រឡឹបក្រឡាប់ខុសពីធម្មតា ថែមទាំងផ្សុំក្លិនគំរង់សាកសពបក់ចេញពីក្នុងបន្ទប់ដេកទៀតផង ធ្វើឱ្យគាត់ចង់ដឹងថា តើមានអ្វីនៅក្នុងបន្ទប់ដេកនេះ បានជានាងហាមមិនឱ្យចូលយ៉ាងនេះ? គិតសព្វគ្រប់ទៅក៏ចេះតែអង្គុយសង្កេតកិរិយារបស់ប្រពន្ធ។ មួយសន្ទុះក្រោយមក ក៏ឃើញនាងលៀនអណ្ដាតយ៉ាងវែងកេវយកវែកដែលជ្រុះទៅលើដី។ ឃើញដូច្នេះប្ដីក៏យល់ថា នាងពិតជាខ្មោចបិសាចប្រែកាយហើយ ទើបគេនឹកឃើញដល់រឿងមនុស្សដែលនិយាយប្រាប់នៅតាមផ្លូវ។

That woman hurried to set a fire to cook rice for her husband, but told her husband not to enter the bedroom, asking him to sleep outside. The husband suspected his wife's strange behavior, since he saw her eyes became big, came out in a reddish way and moved up and down and the unpleasant smell of corpses came from the bedroom. He was curious to see something in the bedroom because his wife banned him from entry. Thinking of everything, he always sat noting at his wife's behaviors. Few minutes later, he saw her sticking her tongue out to pick up the ladle dropping down to the ground. Seeing this, he realized that she must be ghost pretending to be a human and therefore he remembered what the people had told him on the way home.





បុរសនោះក៏ដើរលបៗចូលទៅវែកមុងក្នុងបន្ទប់ដេក ស្រាប់តែឃើញខ្មោចប្រពន្ធកូនខ្លួនស្លាប់ស្អុយរលួយជង្គរ់រុកជ្រិច។ គាត់ក៏ថយចេញមកវិញ ហើយរិះរកមធ្យោបាយដើម្បីរំដោះខ្លួនចេញពីកណ្ដាប់ដៃបិសាចនេះ។ ទើបគាត់និយាយទៅកាន់នាងថា "អូនដាំបាយឱ្យឆ្អិនឆាប់ៗទៅ បងអស់កម្លាំងណាស់ បងចុះទៅនោមមួយភ្លែត"។ ថាហើយគាត់ក៏ទៅចោះក្អមទឹកមួយដែលនៅក្បែរនោះបង្ហូរទឹកទៅលើស្លឹកត្នោតឱ្យឮសូរដូចមនុស្សនោមមែនទែន។ បន្ទាប់មកគាត់ក៏លួចរត់បាតជើងសព្រាតតម្រង់ទៅអារាមមួយដែលមានលោកគ្រូមួយអង្គចេះមន្តអាគមគាថាខ្លាំងពូកែខាងការពារខ្មោចបិសាច និងអាបធ្មប់។

The man crept into the bedroom and suddenly saw the decaying flesh of the corpses of his wife and children. He went out and sought the way to escape from the ghost. "Please cook the rice quickly,' he said to her, 'I am very hungry; I go to urinate for a moment." Then, he poked a small hole in a clay pot in order to pour the water onto the palm tree leaves. It sounded as if the man was urinating. Then he ran as fast as he could towards a pagoda where lived a monk, who was good at magically repressing the evils.

ចំណែកនាងបិសាចវិញ ឮស្គរប្ដីនោមយូរពេកក៏ឆ្ងល់ខ្លាំងណាស់ ទើបនាងដើរទៅមើល។ គ្រាន់តែនាងឃើញប្ដីរត់ទៅផុត នាងក៏រត់តាមក្រោយយ៉ាងលឿនរហូតទាល់តែជិតទាន់។ ចំណែកប្ដីរត់មិនទាន់បានប៉ុន្មានផង ងាកមកក្រោយក៏ឃើញខ្មោចប្រពន្ធកំពុងដេញតាមពីខាងក្រោយក៏ដឹងខ្លួនថា មើលទៅស្ទុះមិនរួចពីកណ្ដាប់ដៃបិសាចនេះទេ ទើបស្ទុះឡើងដើមបាយម៉ាតមួយដើមដែលនៅក្បែរខ្លួន។





នាងបិសាចមិនហ៊ានទៅជិតដើមបាយម៉ាតនោះទេ ចេះតែដើរក្រវែលក្បែរៗ ហើយស្រែកហៅប្ដីឱ្យចុះមក។ បុរសនោះក៏ដឹងថា នាងបិសាចនេះពិតជាខ្លាចដើមបាយម៉ាតនេះហើយ បានជាមិនហ៊ានមកជិតបែបនេះ។ គាត់ក៏កាច់ដើមបាយម៉ាតមួយមែកលីសំដៅទៅវត្តអារាម។

The ghost, hearing her husband urinating too long, then walked to see him. As soon as she saw her husband passing through, she chased him very fast, almost reaching him. when the husband turned back and saw his wife chasing him quickly, he thought that he could not escape from the ghost, so he climbed up a Bay Mat tree (Blumea balsamifera) - a kind of tree believed to be effective in protecting people from ghost haunting - nearby him. The ghost dare not go near Bay Mat tree. She walked round it and called out her husband to come down. The man thought that the ghost might be afraid of Bay Mat tree, so she did not come near. He pruned a branch of the Bay Mat tree, carried it on his shoulder and walked towards a pagoda.

ឯនាងបិសាច ពិតមែនតែមិនហ៊ានទៅជិតបុរសជាប្តី ដោយខ្លាចដើមបាយម៉ាតមែន តែនាងនៅតែដើរតាមក្រោយរហូត។ លុះបុរសនោះទៅដល់វត្ត ក៏រត់ចូលទៅឈប់នៅកណ្តាលជំនុំសង្ឃដែលកំពុងធ្វើឧបោសថកម្មនៅក្នុងព្រះវិហារ ហើយទូលព្រះសង្ឃតាមដំណើរ។ ពេលនោះលោកគ្រូដែលពូកែខាងអាគមគាថា ក៏នាំបុរសនោះទៅនៅក្នុងកុដិរបស់លោក ហើយសូត្រមន្តអាគមគាថាព័ទ្ធសីមាយ៉ាងម៉ឺងម៉ាត់។

Due to the effect of Bay Mat branch, the ghost was afraid to go near the husband, but she still walked after him. When the man arrived at the pagoda, he went to stay in the middle of the crowd of the monks who were reciting and preaching the eight virtues in the temple and told the monks what had happened to him. At that moment, the master of Buddhist monks who was good at using incantations let the man stay in his building and actively cast a spell around it to prevent the ghost from entering.



ឯនាងបិសាចក៏មិនទៅណាឆ្ងាយអំពីកុដិព្រះសង្ឃនោះដែរ។ ពិតមែន តែនាងចូលទៅក្នុងកុដិលោកតាមប្ដីមិនបាន ដោយរបាំងនៃមន្ដអាគមគ ខ្លាំង ប៉ុន្តែនាងចេះតែក្រវែលរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីចូលទៅ តាមប្ដី។ នៅក្បែរកុដិព្រះថេរៈអង្គនោះ មានដើមចេកជ្វាមួយដើមដែល មានធាងទោរចូលនៅត្រង់បង្អួចកុដិ។

The ghost would never went anywhere far from that building. Even though she could not follow her husband into the building because of the incantations, she walked back and forth, exploring any way to reach her husband. Near the master's building was a large banana tree (Chek Chvea) with its branch bowing into its window.



ទោះបីមន្តអាគមរបស់លោកសង្ឃខ្លាំងពូកែយ៉ាងណាក៏ដោយ ក៏មិនអាចទប់ទល់នឹងដើមចេកជ្វានេះបានឡើយ។ លោកព័ទ្ធសីមាបានតែត្រង់កន្លែងណាដែលធាងចេកជ្វាមិនបានទៅប៉ះនឹងសំយ៉ាបកុដិប៉ុណ្ណោះ ចំពោះមួយភាគតូចនៃកុដិរបស់លោកដែលធាងចេកជ្វាទៅប៉ះហើយនោះ ជាឱកាសដ៏ប្រសើរដល់នាងបិសាចនេះហើយ។



Very powerful though was his spell, it could not be stronger than the large banana tree. The spell could have its power only where the branch could not reach the building, but the place touched by the branch was the only way for the ghost to enter the building.

នាងបិសាចក៏ឡើងតាមដើមចេកជ្វា ហើយស្លូតាមធាងចេកនោះឆ្លង ចូលទៅក្នុងកុដិរបស់លោកសង្ឃកាច់កប្តីរបស់ខ្លួនសម្លាប់យ៉ាងព្រៃផ្សៃ ក្នុងពេលនោះទៅ។



The ghost climbed up the large banana tree and went trough its branch into the building and cruelly broke her husband's neck to death right at that moment.

ព្រោះហេតុមានរឿងនិទានមកដូច្នេះហើយ ទើបចាស់បុរាណខ្មែរយើងនិយមជំនឿនេះ ហាមប្រាមកូនចៅមិនឱ្យដាំដើមចេកជ្វានៅជាប់នឹងសំយ៉ាបផ្ទះ ព្រោះគេថាវាដាក់ខ្លួន។ ឯដើមបាយម៉ាត ក៏បានជាឱសថសម្រាប់ការពារមនុស្សមួយមុខយ៉ាងពូកែចំពោះខ្មោចព្រាយបិសាច និងអាបធ្មប់ជាប់រហូតមកដល់សព្វថ្ងៃនេះ។ **ចប់**



Because there was such narrative, the ancient Cambodian people generally believed it and banned their descendents from growing the large banana trees adjacent to the end pieces of house roofs because it could bring bad luck to them. As for the Bay Mat trees, they have become a good medicine to prevent the evils or ghosts up to now. **The End**